00644955

E9/7

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់លោក អៀង សារី សុំបន្ថែមពេលវេលាដើម្បីដាក់ការជំទាស់ទៅលើសាក្សី, ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើដោយ កសព**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ផ្ញើជូន៖</u> |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្ដម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្តារ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 02 / 2011
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះ សូមដាក់ជូននូវសំណើជាបន្ទាន់របស់លោក អៀង សារី សុំបន្ថែមពេលវេលាដើម្បីដាក់ការជំទាស់ទៅលើ សាក្សី, ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើដោយការិយាល័យសហព្រះរាជអាជ្ញា(“កសព”) ។ សំណើសុំនេះចាំបាច់ត្រូវធ្វើឡើងព្រោះថា ដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់អោយភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (“ដីកាបង្គាប់”)[1] តម្រូវអោយ កសព ដាក់នូវសេចក្តីសង្ខេបនៃគុណសម្បត្តិ និងលក្ខណៈជំនាញនៃអ្នកជំនាញដែលបានស្នើឡើង[2] និងសេចក្តីសង្ខេបនៃអង្គហេតុទាំងឡាយដែលរំពឹងថានឹងធ្វើសក្ខីកម្មដោយអ្នកជំនាញដែលបានស្នើឡើង ឬ សេចក្តីសង្ខេបនៃអង្គហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនឹងត្រូវស្តាប់យកចម្លើយ ទាក់ទងនឹងអង្គហេតុនានា ឬ ផលប៉ះពាល់ដែលបណ្តាលមកពីបទល្មើសដែលបានចោទប្រកាន់[3]។ ដីកាបង្គាប់តម្រូវអោយដាក់សេចក្តីសង្ខេបទាំងនេះរហូតដល់ថ្ងៃ ២៣ កុម្ភៈ ២០១១[4] ហើយមកទល់ពេលនេះ កសព មិនទាន់ដាក់នូវសេចក្តីសង្ខេបទាំងនេះឡើយ[5]។ ចាប់ពីពេលនេះរហូតដល់ពេលសេចក្តីសង្ខេបទាំងនេះត្រូវបានដាក់ មេធាវីការពារក្តីមានតែទស្សនៈស្រពិចស្រពិលទាក់ទងនឹងថាអ្វីបានជាគេស្នើនូវសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនេះឡើង ហើយថាតើអ្នកជំនាញដែលបានស្នើឡើងមានគុណសម្បត្តិអ្វីខ្លះ។ កាលបរិច្ឆេទកំណត់ដើម្បីជំទាស់នឹងបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងនេះគឺថ្ងៃទី ២៨ កុម្ភៈ ២០១១[6]។ បើសិនជា កសព ដាក់សេចក្តីសង្ខេបនៅត្រឹមកាលបរិច្ឆេទកំណត់ ហើយបើសិនជាគេជូនដំណឹងដល់មេធាវីការពារក្តីភ្លាម នោះមេធាវីការពារក្តីនៅសល់ពេលតែ ៥ថ្ងៃប៉ុណ្ណោះ គិតទាំងចុងសប្តាហ៍ ដើម្បីសម្រេចថាតើអ្នកណាខ្លះត្រូវជំទាស់ ហើយត្រូវព្រាងតាក់តែង បកប្រែ និងដាក់នូវការជំទាស់នេះ។ វាមិនមានពេលវេលាគ្រប់គ្រាន់ ជាពិសេស

---

[1] *ករណីលោក* នួន ជា, សំណុំរឿង 00២-១៩-0៩-២00៧-អវតក/អជសដ, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១, ឯកសារ E9, ERN: 00635754-00635759 ។

[2] *ដូចខាងលើ* កថាខណ្ឌទី ៦(ii) ។

[3] *ដូចខាងលើ* កថាខណ្ឌទី ៦(i) ។

[4] *ដូចខាងលើ* កថាខណ្ឌទី ៦ ។

[5] កសពស គួរតែអាចផ្តល់ព័ត៌មាននេះនៅមុនកាលកំណត់។ កសព ត្រូវតែមាននេះច្រើនបើសិនជាមិនមានទាំងអស់ នៅដំណាក់កាលនេះ។ ឧទាហរណ៍ មានអ្នកជំនាញម្នាក់ក្នុងអ្នកជំនាញទាំងឡាយដែលស្នើឡើងគឺជាបុគ្គលិករបស់ កសព ហើយ កសព ធ្លាប់បានស្នើឡើងម្តងនូវមនុស្សមួយចំនួនដដែលនេះទៅ កសចស នៅក្នុងដំណាក់កាលស៊ើបសួរនៅក្នុងសំណុំរឿង 00២។ *សូមមើលករណីលោក* នួន ជា, សំណុំរឿង 00២-១៩-0៩-២00៧-អវតក/កសចស, សំណើរបស់សហព្រះរាជអាជ្ញាសុំតែងតាំងអ្នកជំនាញ , ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២00៩, ឯកសារ D281, ERN: 00417039-00417048 ។

[6] ដីកាបង្គាប់ កថាខណ្ឌទី៨ ។

ដោយពិចារណាថា អង្គភាពបកប្រែឯកសារផ្ទាល់មាត់ និង សរសេរ ("ITU") មិនធ្វើការនៅចុងសប្តាហ៍ទៀតនោះ។ ហេតុដូច្នេះ មេធាវីការពារក្តី ស្នើសុំការបន្ថែមពេលវេលារហូតដល់ថ្ងៃទី ១១ មីនា ២០១១ ដើម្បីដាក់នូវការជំទាស់នេះ។ លោក អៀង សារី ត្រូវតែបានគេផ្តល់អោយនូវសិទ្ធិជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់ ដើម្បីទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំកិច្ចការពារក្តីរបស់គាត់។

## I. ច្បាប់ជាធរមាន

១. មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងថា:

សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃកតិសញ្ញាអន្តរជាតិឆ្នាំ១៩៥៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងនីតិវិធីនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ និង<u>សិទ្ធិទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការការពារ</u> សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និសិទ្ធិពិនិត្យសាក្សីដាក់បន្ទុក[7] ។

២. មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

ក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមានិងស្មើៗគ្នាស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ...(ខ)<u>មានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីដែលខ្លួនជ្រើសរើសដោយខ្លួនឯង</u>...[8]។

៣. មាត្រា ១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែង<u>ក្នុងផ្នែកពាក់ព័ន្ធ</u>ថា៖

ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមាន

---

[7] បញ្ជាក់បន្ថែម ។

[8] គូសបញ្ជាក់បន្ថែម។

សិទ្ធិទទួលបានការធានាជាអប្បរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ៖ ... (ខ)ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង... ។

៤. មាត្រា ១១ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា៖ "ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈដែលមានការធានាចាំបាច់ ដើម្បីការពារសិទ្ធិជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ"។

## II. អំណះអំណាង

៥. មេធាវីការពារក្តី សូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាបន្ថែមពេលវេលាកំណត់ទៅដល់ថ្ងៃទី ១១ មីនា ២០១១ ដើម្បីដាក់ការជំទាស់ទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើឡើងដោយ កសព ។ ការអនុញ្ញាតនេះគឺស្ថិតនៅក្នុងអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៣៩(៤)(ក) [9]។ មេធាវីការពារក្តី មិនអាចសម្រេចថា តើការជំទាស់មានលក្ខណៈចាំបាច់ឬអត់ លុះត្រាដល់ពេលមានការជូនដំណឹងថាតើសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ នឹងត្រូវធ្វើសក្ខីកម្មទៅលើអ្វី ហើយអ្នកជំនាញដែលបានស្នើឡើងនោះមានគុណសម្បត្តិអ្វីខ្លះ។ សាក្សីទាំងឡាយអាចត្រូវបានជំទាស់បើសិនជាការស្តាប់យកចម្លើយអ្នកទាំងនេះមិននាំទៅដល់ការរកការពិតទេ។ ជាក់ស្តែងវាពិតជាមិនអាចជំទាស់ទៅលើសាក្សីដែលបានស្នើឡើងឡើយ លុះត្រាដល់ពេលមេធាវីការពារក្តីត្រូវបានគេជូនដំណឹងថាតើអង្គហេតុអ្វីខ្លះ ដែលសាក្សីនឹងធ្វើសក្ខីកម្ម។ បើសិនជាគ្មានព័ត៌មានទាំងនេះទេ មេធាវីការពារក្តីមិនអាចដឹងថា តើការស្តាប់យកចម្លើយសាក្សីទាំងនេះនឹងនាំទៅរកការពិតដែរឬអត់។ អ្នកជំនាញទាំងឡាយ អាចនឹងត្រូវជំទាស់ដោយឈរលើមូលដ្ឋានថាអ្នកជំនាញទាំងនេះខ្វះនូវចំណេះដឹងជំនាញ ឬ បទពិសោធពិសេសដើម្បីជាជំនួយដល់អង្គជំនុំជម្រះសាលាដំបូង។ វាពិតជាមិនអាចជំទាស់ទៅលើអ្នកជំនាញនានាដែលបានស្នើឡើងឡើយ លុះត្រាតែគេបានជូនដំណឹងអំពីគុណសម្បត្តិរបស់អ្នកជំនាញទាំងនេះ។

---

[9] វិធាន ៣៩(៤)(ក) ចែងថា "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចៈ ក-ពន្យាពេលវេលាកំណត់ ដែលខ្លួនបានសម្រេច"។

៦. ដីកាបង្គាប់តម្រូវអោយភាគីទាំងឡាយ ដែលមានបំណងជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ បង្ហាញថាហេតុអ្វីភាគីធ្វើការជំទាស់ មិនមែនត្រឹមតែអះអាងការជំទាស់តែមួយមុខប៉ុណ្ណោះទេ[10]។ បើសិនជាមេធាវីការពារក្តី មិនត្រូវបានអនុញ្ញាតអោយមានពេលវេលាបន្ថែមទេ ការណ៍នេះនឹងបង្ខំអោយមេធាវីការពារក្តី ទស្សទាយថាតើ និង ហេតុអ្វីការជំទាស់មួយចំនួនមានលក្ខណៈចាំបាច់។ មេធាវីការពារក្តី មិនអាចការពារក្តីលោក អៀង សារី អោយបានគត់មត់ទេ បើសិនជាមេធាវីការពារក្តី ត្រូវបានគេរំពឹងអោយមានមូលដ្ឋាននៃការជំទាស់របស់ខ្លួនទៅលើការប៉ាន់ស្មានតែមួយមុខគត់នោះ។ មេធាវីការពារក្តី ទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញថា អង្គជំនុំជម្រះ "នឹងធ្វើការពិចារណាថាតើខ្លួនមានបំណងស្នើអោយភាគីដែលជំទាស់នោះដាក់នូវសារណាបន្ថែមដែរឬទេ"[11]។ មេធាវីការពារក្តី ក្នុងការបំពេញកិច្ចប្រកបដោយវីរិយភាព មិនអាចដាក់នូវការជំទាស់ដោយផ្អែកទៅលើការប៉ាន់ស្មានតែមួយមុខនៅដំណាក់កាលនេះទេ ហើយសង្ឃឹមថាខ្លួននឹងត្រូវបានអនុញ្ញាតអោយដាក់សារណាបន្ថែម នៅពេលណាដែលមេធាវីការពារក្តី មាននូវព័ត៌មានចាំបាច់ទាំងអស់ឡើយ។ ការជំទាស់បែបនេះ មិនអាចជាជំនួយដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីសម្រេចថាតើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញណាខ្លះ ដែលអង្គជំនុំជំម្រះសាលាដំបូង មានបំណងកោះហៅដើម្បីមកធ្វើសក្ខីកម្មឡើយ។ ម្យ៉ាងទៀត រឿងនេះនឹងបណ្តាលអោយខ្ជះខ្ជាយនូវធនធាន ព្រោះថា ITU នឹងតម្រូវអោយបកប្រែពីរដងព្រោះមានឯកសារច្រើន។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលទាំងអស់ដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា**បន្ថែម**ពេលវេលាកំណត់ជាធរមានរហូតដល់ថ្ងៃទី ១១ មីនា ២០១១ ដើម្បីជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើឡើងដោយ កសព។

សូមលោកចៅក្រមអង្គជំនុំសាលាដំបូងទទួលសេចក្តីជូនដំណឹងនេះដោយក្តីគោរព។

---

[10] ដីកាបង្គាប់ កថាខណ្ឌ ៨ ។

[11] *ដូចខាងលើ* ។

00644960



ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៦** ខែ **កុម្ភៈ** ឆ្នាំ **២០១១**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**